

## រឿងទី៩៖ ដានីយ៉ែល

**ខគម្ពីរ៖ ដានីយ៉ែល៦៖២៧**

ព្រះអង្គសង្គ្រោះ និងរំដោះមនុស្សលោក ព្រះអង្គសម្ដែងទីសម្គាល់ និងឫទ្ធិបាដិហារិយ៍ នៅលើមេឃ និងនៅលើផែនដី គឺព្រះអង្គនេះហើយដែលបានសង្គ្រោះ លោកដានីយ៉ែលឲ្យរួចពីក្រញាំតោ»។

ក្រោយព្រះបាទនេប៊ូក្នេសាបានសោយទីវង្គត ព្រះបាទដារីយ៉ូសក៏បានឡើងគ្រងរាជដឹកនាំស្រុកបាប៊ីឡូន។
ព្រះបាទដារីយ៉ូស ពេញចិត្តនឹងដានីយ៉ែលដោយព្រោះលោកមានប្រាជ្ញា ព្រះរាជាបានតែងតាំងដានីយ៉ែលជា នាយករដ្ឋមន្ត្រី។ ប៉ុន្តែ ពួកមន្ត្រីផ្សេងទៀតមិនពេញចិត្តដានីយ៉ែលទេ។
ពួកមន្ត្រីទាំងអស់បានរកឃើញពីចំណុចខ្សោយរបស់ដានីយ៉ែល ប៉ុន្តែគ្មានវិធីដាក់ទោសដានីយ៉ែលដែលគ្មានទោស នោះទេ។
ដូច្នេះ ពួកមន្ត្រីក៏ដាក់សំណើរមួយទូលទៅព្រះរាជា។
«បពិត្រព្រះរាជា សព្វថ្ងៃនេះមនុស្សខ្លះមិនគោរពកោតខ្លាចទ្រង់ដែលជាស្ដេចផែនដីទេបែរជាថ្វាយបង្គំ ហើយបម្រើដល់ព្រះ និងមនុស្សផ្សេងទៅវិញ។
សូមទ្រង់ចេញជាច្បាប់មួយឱ្យមនុស្សទាំងអស់មកថ្វាយបង្គំតែព្រះមហាក្សត្រមួយអង្គរយៈពេល៣០ថ្ងៃទៅ។
បើមានអ្នកណាថ្វាយបង្គំព្រះផ្សេងទៀត នោះត្រូវតែបោះពួកគេចូលទៅក្នុងរូងតោ»។
ព្រះបាទដារីយូស បានចេញច្បាប់ថ្មី ប្រថាប់ត្រាហើយប្រកាសប្រាប់ដល់ប្រជារាស្ត្រទាំងអស់ឱ្យដឹង។
ដានីយ៉ែលបានឮដំណឹងនោះ ប៉ុន្តែ លោកនៅតែធ្វើដូចរាល់ដង លុតជង្គង់ថ្វាយបង្គំព្រះជាម្ចាស់មួយថ្ងៃបីដង អធិស្ឋានអរព្រះគុណព្រះជាម្ចាស់មិនដែលខាន។
មានមន្ត្រីម្នាក់បានយករឿងទៅទូលថ្វាយព្រះរាជា។
«សូមទ្រង់ចេញបញ្ជាចាប់ដានីយ៉ែលបោះចូលទៅក្នុងរូងតោទៅ ព្រោះដានីយ៉ែលល្មើសនឹងច្បាប់ ដោយនៅតែអធិស្ឋានទៅកាន់ព្រះរបស់គេដដែល»។
ព្រះរាជា ពេញចិត្តដានីយ៉ែលណាស់ ប៉ុន្តែដោយព្រោះដានីយ៉ែលបានល្មើសនិងច្បាប់ដូច្នេះ ទ្រង់ក៏សម្រេចឱ្យគេចាប់ ដានីយ៉ែលបោះចូលទៅក្នុងរូងតោទៅ»។
ព្រះរាជាបានមានបន្ទូលទៅដានីយ៉ែលថា៖ «ព្រះរបស់អ្នក ដែលអ្នកតែងតែគោរពកោតខ្លាច នឹងជួយសង្គ្រោះអ្នកជាមិនខាន»។
ដានីយ៉ែលនៅតែបន្តអធិស្ឋានទៅព្រះជាម្ចាស់ ទោះកំពុងស្ថិតនៅក្នុងរូងតោក៏ដោយ។
ព្រះរាជា ព្រួយបារម្ភពីដានីយ៉ែលខ្លាំងពេក ទ្រង់មិនសោយ មិនផ្ទំ។ ថ្ងៃបន្ទាប់ ព្រះរាជា បានក្រោកតាំងពីព្រលឹម យាងទៅរូងតោដែលស្រេកឃ្លាន។
ទ្រង់ទតឃើញដានីយ៉ែលនៅក្នុងរូងតោយ៉ាងសុខសាន្ត។ ហើយឃើញតោដែលស្រេកឃ្លានទាំងនោះដេកក្បែរការពារដានីយ៉ែល។
ព្រះរាជាមានការសប្បាយរីករាយជាខ្លាំង។ ហើយបានឱ្យគេស្វែងរកអ្នកដែលធ្វើបាបដានីយ៉ែលទាំងអស់។
ព្រះរាជាខឹងក្រោធជាខ្លាំង ហើយបានបោះពួកមន្ត្រីនិងគ្រួសាររបស់ពួកគេចូលទៅក្នុងរូងតោ។
ព្រះរាជា បានចេញបញ្ជាឱ្យប្រជារាស្ត្រទាំងអស់គោរពថ្វាយបង្គំព្រះដែលដានីយ៉ែលគោរពថ្វាយបង្គំ។
ក្រោយពីនោះមក ដានីយ៉ែលគោរពបម្រើ និងថ្វាយបង្គំតែព្រះជាម្ចាស់មួយអង្គគត់ ហើយគាត់បានរស់នៅយ៉ាងសុខ សាន្ត។





**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើពួកមន្ត្រីបាប៊ីឡូនបានស្នើអ្វីខ្លះ ដើម្បីដាក់ទោសលោកដានីយ៉ែល?

---

b. តើលោកដានីយ៉ែលបានដឹងថាពួកមន្ត្រីបាប៊ីឡូនចង់ធ្វើបាបលោក ប៉ុន្តែលោកនៅតែធ្វើកិច្ចការប្រចាំថ្ងៃរបស់លោកដដែល តើកិច្ចការនោះជាអ្វី?

---

c. សូមអានដានីយ៉ែល៦៖១៦-២៣ រួចសូមឆ្លើយសំណួរ។ តើស្តេចបានមានព្រះបន្ទូលថាដូចម្តេចទៅលោកដានីយ៉ែល នៅពេលដែលលោកត្រូវបានគេបោះចូលទៅក្នុងរូងតោ? ហើយតើមានអ្វីកើតឡើងនៅពេលលោកដានីយ៉ែលនៅក្នុងរូងតោ?

---

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (ដានីយ៉ែល ៦៖២៧)

ព្រះអង្គសង្គ្រោះ និងរំដោះមនុស្សលោក ព្រះអង្គសម្តែងទីសម្គាល់ និងឫទ្ធិបាដិហារិយ៍ នៅលើមេឃ និងនៅលើផែនដី គឺព្រះអង្គនេះហើយដែលបានសង្គ្រោះលោកដានីយ៉ែលឲ្យរួចពីក្រញាំតោ»។





**សកម្មភាពទី២** សូមសរសេរសុំណូមពរអធិស្ឋាន ៥ចំណុច របស់អ្នក។

## សុំណូមពរអធិស្ឋាន

- ................................................................................................................................................................................................................................................
- ................................................................................................................................................................................................................................................
- ................................................................................................................................................................................................................................................
- ................................................................................................................................................................................................................................................
- ................................................................................................................................................................................................................................................



